ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

លេខ៖ ២៤៧ / ម.ជ.ម. / ២៤

# សេចក្តីណែនាំ
# ស្តីពី
# ការប្រើប្រាស់យន្តការដោះស្រាយវិវាទ តាមរយៈសន្ទានកម្ម-មជ្ឈត្តការ (Med-Arb) របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** (ម.ជ.ម.) សង្កេតឃើញថា យន្តការដោះស្រាយវិវាទតាមរយៈសន្ទានកម្ម និងមជ្ឈត្តការ ត្រូវបានប្រើប្រាស់ក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មទាំងនៅ ក្នុងស្រុក និងអន្តរជាតិ។ យន្តការសន្ទានកម្ម-មជ្ឈត្តការ (Med-Arb) គឺជាដំណើរការនៃការដោះស្រាយវិវាទ ដែលគូភាគីព្យាយាមដោះស្រាយវិវាទដោយសន្ទានកម្ម មុននឹងបញ្ជូនវិវាទនោះទៅដោះស្រាយជាស្ថាពរដោយមជ្ឈត្តការ។

ក្នុងករណី គូភាគីមានបំណងប្រើប្រាស់យន្តការដោះស្រាយវិវាទ តាមរយៈសន្ទានកម្ម-មជ្ឈត្តការ (Med-Arb) ដែលចាត់ចែងដោយ ម.ជ.ម. គូភាគីអាចពិចារណាបញ្ចូលខចែងស្តីពីសន្ទានកម្ម-មជ្ឈត្តការ (Med-Arb Clause) នៅក្នុងកិច្ចសន្យារបស់ខ្លួនដូចខាងក្រោម៖

**ជម្រើសទី ១៖ គំរូខចែងស្តីពីសន្ទានកម្ម-មជ្ឈត្តការ (Med-Arb Clause)**

(X) រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ជាដំបូងត្រូវបញ្ជូនទៅដោះស្រាយតាមរយៈសន្ទានកម្ម ដែលចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីសន្ទានកម្មរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីសន្ទានកម្មរបស់ ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការសន្ទានកម្ម ហើយតាមរយៈការយោងនៅក្នុងប្រការនេះ វិធានស្តីពីសន្ទានកម្មរបស់ ម.ជ.ម. ត្រូវចាត់ទុកថាបាន រួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។ ការចាប់ផ្តើមនីតិវិធីសន្ទានកម្មមិនរារាំងដល់ភាគីវិវាទក្នុងការចាប់ផ្តើមនីតិវិធីមជ្ឈត្តការស្របតាមប្រការ (Y) ខាងក្រោមឡើយ។

(Y) រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ ចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការ


ជាន់ទី៣៧ អគារ GIA Tower ផ្លូវសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
37th Floor, GIA Tower, Street Sopheak Mongkul, Tonle Bassac, Chamkarmon, Phnom Penh, Cambodia
T: +855 96 888 5333 | E: info@ncac.org.kh | W: www.ncac.org.kh

យោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករ ចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

គូភាគីអាចពិចារណាអំពីប្រការបន្ថែមដូចខាងក្រោម៖

**១. ភាសាសម្រាប់សន្ធានកម្ម**

ភាសាសម្រាប់ដំណើរការសន្ធានកម្មគឺ [ជ្រើសរើសភាសា]។

**២. ទីកន្លែងសន្ធានកម្ម**

ទីកន្លែងសម្រាប់សន្ធានកម្មគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។***

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________****។

**សម្គាល់៖** ខចែងនេះបង្កើតកាតព្វកិច្ចក្នុងការដោះស្រាយវិវាទដោយសន្ធានកម្ម ក្រោមវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.។ ខចែងនេះធានាថា នៅពេលមានវិវាទកើតឡើង គូភាគីនឹងព្យាយាមដោះស្រាយវិវាទរបស់ខ្លួនស្របតាមវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.។ ខចែងនេះ ក៏បានបង្ហាញច្បាស់ថា គូភាគីមិនចាំបាច់បញ្ចប់ដំណើរការសន្ធានកម្ម ឬរង់ចាំបញ្ចប់រយៈពេលណាមួយ មុនពេលគូភាគីអាចចាប់ផ្តើមដំណើរការមជ្ឈត្តការនោះឡើយ។

**ជម្រើសទី ២៖ គំរូខចែងស្តីពីសន្ធានកម្ម-មជ្ឈត្តការ (Med-Arb Clause)**

(X) រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះ ជាដំបូងត្រូវបញ្ជូនទៅដោះស្រាយតាមរយៈសន្ធានកម្ម ដែលចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីសន្ធានកម្ម របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការសន្ធានកម្ម ហើយតាមរយៈការយោងនៅក្នុងប្រការនេះ វិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.

ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។ ក្នុងករណីដែលវិវាទនោះមិនអាចដោះស្រាយ ស្របតាមវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម. ក្នុងរយៈពេល [៤៥] ថ្ងៃប្រតិទិន ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមសន្ធានកម្ម ឬក្នុងអំឡុងពេលណាមួយផ្សេងទៀតដែលព្រមព្រៀងដោយគូភាគីជាលាយលក្ខណ៍អក្សរ ភាគីវិវាទអាចចាប់ផ្តើមនីតិវិធីមជ្ឈត្តការស្របតាមប្រការ (Y) ខាងក្រោម។

(Y) រាល់វិវាទទាំងអស់ដែលកើតចេញពី ឬដែលទាក់ទងនឹងកិច្ចសន្យានេះ រួមបញ្ចូលវិវាទទាំងឡាយដែលពាក់ព័ន្ធនឹងអត្ថិភាព សុពលភាព ការអនុវត្ត ឬការបញ្ចប់កិច្ចសន្យានេះត្រូវបញ្ជូនទៅដោះស្រាយជាស្ថាពរតាមរយៈមជ្ឈត្តការ ចាត់ចែងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ស្របតាមវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.) ដែលមានសុពលភាពអនុវត្ត នៅពេលចាប់ផ្តើមដំណើរការមជ្ឈត្តការ ហើយតាមរយៈការយោងក្នុងប្រការនេះ វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ត្រូវចាត់ទុកថាបានរួមបញ្ចូលជាផ្នែកមួយនៃកិច្ចសន្យានេះ។

ទីកន្លែងធ្វើមជ្ឈត្តការគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។*

វេទិកាមជ្ឈត្តកម្មត្រូវមានមជ្ឈត្តករ ចំនួន__________**រូប។

ភាសានៃមជ្ឈត្តការគឺ ________________ ។

គូភាគីអាចពិចារណាអំពីប្រការបន្ថែមដូចខាងក្រោមៈ

**១. ភាសាសម្រាប់សន្ធានកម្ម**

ភាសាសម្រាប់ដំណើរការសន្ធានកម្មគឺ [ជ្រើសរើសភាសា]។

**២. ទីកន្លែងសន្ធានកម្ម**

ទីកន្លែងសម្រាប់សន្ធានកម្មគឺ [រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]។***

**ខចែងស្តីពីច្បាប់គ្រប់គ្រងកិច្ចសន្យា**

ច្បាប់ដែលត្រូវយកមកអនុវត្តលើកិច្ចសន្យានេះគឺច្បាប់នៃ________________****។

**សម្គាល់៖** ខចែងនេះបង្កើតកាតព្វកិច្ចក្នុងការដោះស្រាយវិវាទដោយសន្ធានកម្ម ក្រោមវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម.។ ខចែងនេះធានាថា នៅពេលមានវិវាទកើតឡើង គូភាគីនឹងព្យាយាមដោះស្រាយវិវាទរបស់ខ្លួនស្របតាមវិធានស្តីពីសន្ធានកម្មរបស់ ម.ជ.ម. ក្នុងអំឡុងពេល [៤៥] ថ្ងៃប្រតិទិន ឬក្នុងអំឡុងពេលណាមួយផ្សេងទៀតដែលព្រមព្រៀងដោយគូភាគីជាលាយលក្ខណ៍អក្សរ។ ខចែងនេះ ក៏បានបង្ហាញច្បាស់ថា គូភាគីមិនអាចចាប់ផ្តើមដំណើរការមជ្ឈត្តការបានឡើយ ប្រសិនអំឡុងក្នុងការដោះស្រាយវិវាទតាមរយៈសន្ធានកម្មកំណត់ខាងលើមិនទាន់ត្រូវបានផុតនោះ។

---

* គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើស នៃទីកន្លែងធ្វើមជ្ឈត្តការរបស់ខ្លួន។ ប្រសិនបើគូភាគី វិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើមជ្ឈត្តការផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស ]" )។

** ចំនួនមជ្ឈត្តករត្រូវកំណត់ជាចំនួនសេស។

*** គូភាគីវិវាទគួរបញ្ជាក់អំពីជម្រើសនៃទីកន្លែងធ្វើសន្ធានកម្មរបស់ខ្លួន។ ប្រសិនបើគូភាគីវិវាទមានបំណងចង់ជ្រើសរើសទីកន្លែងធ្វើសន្ធានកម្មផ្សេងពីរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គូភាគីវិវាទត្រូវជំនួស "[រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា]" ដោយឈ្មោះទីក្រុង និងប្រទេសនៃជម្រើសរបស់ខ្លួន (ឧទាហរណ៍ "[ទីក្រុង ប្រទេស"])។

**** បញ្ជាក់ឈ្មោះប្រទេស ឬយុត្តាធិការ។

សម្រាប់ព័ត៌មានបន្ថែម អំពីយន្តការដោះស្រាយវិវាទ តាមរយៈសន្ធានកម្ម-មជ្ឈត្តការ (Med-Arb) ដែលចាត់ចែងដោយ ម.ជ.ម. សូមទំនាក់ទំនងមកអគ្គលេខាធិការដ្ឋាន ម.ជ.ម. តាមរយៈលេខទូរសព្ទ៖ (+៨៥៥) ៩៦ ៨៨៨ ៥៣៣៣ ឬតាមរយៈអ៊ីម៉ែល៖ info@ncac.org.kh នៅរៀងរាល់ម៉ោងធ្វើការ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ២ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤

**មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម**

**ប្រធាន**

NATIONAL COMMERCIAL ARBITRATION CENTRE

មជ្ឈត្តករ សាន គិរី